# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥០.សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការវាយតំលៃការដេញថ្លៃ ក្នុងការជ្រើសរើសក្រុមហ៊ុនគ្រប់គ្រងនាវាសញ្ចរណ៍អាកាសកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- យោងតាមសេចក្តីត្រូវការចាំបាច់របស់រាជរដ្ឋាភិបាលក្នុងការជ្រើសរើសក្រុមហ៊ុនគ្រប់គ្រងនាវាសញ្ចរណ៍កម្ពុជា

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការវាយតំលៃការដេញថ្លៃ ក្នុងការជ្រើសរើសក្រុមហ៊ុនគ្រប់គ្រងនាវាសញ្ចរណ៍កម្ពុជា ។

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តម | **សេង** | **ហើមនៅ** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | **ញាណ** | **ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម | **ឡេង** | **អនយុត្តរា** | អគ្គនាយកដឹកជញ្ជូននៃក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៤- បណ្ឌិត | **ជា** | **ច័ន្ទរ៉េត** | ជំនួយការឯកឧត្តមទេសរដ្ឋមន្ត្រី សុខ អាន | សមាជិក |
| ៥- លោក | **ឃុយ** | **ហៀង** | អនុប្រធាននាយកដ្ឋានគមនាគមន៍ | សមាជិក |

**ប្រការ២ :** គណៈកម្មការមានភារកិច្ចពិនិត្យ ស្រាវជ្រាវ និងវាយតំលៃការដេញថ្លៃ ក្នុងការជ្រើសរើសក្រុមហ៊ុន ដែលមានបទពិសោធន៍គួរអោយទុកចិត្ត និងមានសមត្ថភាព ក្នុងការងារគ្រប់គ្រងនាវាសញ្ចរណ៍កម្ពុជា ។

**ប្រការ៣ :** ឯកឧត្តម អស់លោក ដូចមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយបានលទ្ធផលល្អ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០២

ហ៊ុន សែន

ចំលងជូន :
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ឯកសារ-កាលប្បវត្តិ